**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ ០១៣ សហវ

# សេចក្តីណែនាំ

## ស្តីពី

## ការកែសម្រួលនីតិវិធីបង់ចំណូលថវិកាពន្ធគយនិងរដ្ឋាករ ទាំងសាច់ប្រាក់និងមិនមែនសាច់ប្រាក់ ពីការប្រើប្រាស់ឯកសារជាក្រដាស ទៅជាឯកសារឌីជីថល តាមរយៈសន្ធានកម្មទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ

ក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តរួចរាល់នូវសន្ធានកម្មផ្លាស់ប្តូរទិន្នន័យដោយស្វ័យប្រវត្តិ រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយដោយជោគជ័យ ដើម្បីពន្លឿនការទទួលស្គាល់ចំណូលថវិកាជាតិ និង បង្កើននូវសង្គតិភាព និង ភាពជឿទុកចិត្តនៃទិន្នន័យចំណូលពន្ធគយនិងរដ្ឋាករ រវាងប្រព័ន្ធទាំងពីរ។ បន្ទាប់ពីបានអនុវត្តនូវសន្ធានកម្មរវាងប្រព័ន្ធទាំងពីរខាងលើរួចមក សលាកបត្របង់ចំណូលថវិកាពន្ធគយនិងរដ្ឋាករ (ជាក្រដាស) ត្រូវបានឈប់ប្រើប្រាស់សម្រាប់ករណីចំណូលសាច់ប្រាក់ ដែលជំនួសដោយទិន្នន័យពីសន្ធានកម្ម ការបញ្ជូនសលាកបត្រក្នុងទម្រង់ជាឌីជីថល និង ការរៀបចំជាដីកាសម្រង់សលាកបត្របង់ចំណូលថវិកាប្រចាំខែ ជាក្រដាស ដើម្បីជាមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់។ ដោយឡែក សលាកបត្របង់ចំណូលថវិកាទូទាត់ប្រាក់រង្វាន់ និងរបាយការណ៍ផ្គូផ្គងចំណូលថវិកាជាតិប្រចាំឆ្នាំ គឺនៅប្រើប្រាស់ជាឯកសារក្រដាសនៅឡើយ។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំដល់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និង អគ្គនាយកដ្ឋានរតនាគារជាតិ រួមទាំង អង្គភាពនៅក្រោមឱវាទនៃអគ្គនាយកដ្ឋានទាំងពីរដែលមានការពាក់ព័ន្ធដូចតទៅ៖

១. បន្តអនុវត្តនីតិវិធីបញ្ជូនសលាកបត្របង់ចំណូលថវិកាជាសាច់ប្រាក់ដូចការអនុវត្តបច្ចុប្បន្ន ក្នុងទម្រង់ជាឯកសារឌីជីថល ប៉ុន្តែត្រូវបន្តគិតគូរបង្កើននូវភាពស្វ័យប្រវត្តិកម្មបន្ថែមទៀតទៅលើវិធាននៃការបញ្ជូនឯកសារឌីជីថលនេះ ឬ អាចផ្តល់ជាតំណភ្ជាប់ក្នុងការចូលទៅកាន់សលាកបត្រនីមួយៗបាន ភ្ជាប់ជាមួយនឹងប្រតិបត្តិការចំណូលដែលបានបញ្ជូនទៅកាន់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយធានាឱ្យបាននូវសង្គតិភាព និង សុក្រឹតភាពនៃទិន្នន័យដែលបានបញ្ជូនតាមសន្ធានកម្ម ។

២. អនុវត្តនីតិវិធីដូចគ្នានឹងចំណុចទី ១ ខាងលើ សម្រាប់ការរៀបចំនូវដីកាសម្រង់សលាកបត្របង់ចំណូលថវិកាប្រចាំខែ សម្រាប់ជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់តែប៉ុណ្ណោះ ដោយមិនមានតម្រូវឱ្យរៀបចំឯកសារជាក្រដាសឡើយ ។

៣. អនុវត្តនីតិវិធីដូចគ្នានឹងចំណុចទី ១ ខាងលើ សម្រាប់ការរៀបចំសលាកបត្របង់ចំណូលថវិកាទូទាត់ប្រាក់រង្វាន់ ដោយមិនតម្រូវឱ្យមានការរៀបចំឯកសារជាក្រដាសនោះទេ ។

៤.អគ្គនាយកដ្ឋានរតនាគារជាតិ ឬ រតនាគាររាជធានី-ខេត្ត ត្រូវបន្តអនុវត្តនីតិវិធីនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន បន្ទាប់ពីទទួលបានទិន្នន័យចំណូលពន្ធគយនិងរដ្ឋាករពីសន្ធានកម្មគ្រប់មុខសញ្ញា ដោយមិនមានការរង់ចាំឯកសារជាក្រដាសទៀតនោះឡើយ ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ រតនាគាររាជធានី-ខេត្ត សាខា ឬ ការិយាល័យគយនិងរដ្ឋាករ និង គ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២២ តទៅ ។

ថ្ងៃអង្គារ ៧រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានរតនាគារជាតិ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ